ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភាព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខ ១០២

ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២២

សាលដីកា

លេខ ២៦៧ "II"

ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២២

# សាលដីកា

## តាងនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២២

ដោយអង្គជំនុំជម្រះមានសមាសភាពដូចខាងក្រោម ៖

១. ឯកឧត្តម [redacted] ជាប្រធាន

២. ឯកឧត្តម [redacted] ជាចៅក្រម

៣. ឯកឧត្តម [redacted] ជាចៅក្រម

៤. ឯកឧត្តម [redacted] ជាចៅក្រម

៥. លោកជំទាវ [redacted] ជាចៅក្រមរបាយការណ៍

## ក្រឡាបញ្ជីសវនាការ

លោក [redacted]

## តំណាងមហាអយ្យការ

ឯកឧត្តម [redacted] ជាព្រះរាជអាជ្ញា

## ដើម្បីជំនុំជម្រះ

លើបណ្តឹងសាទុក្ខលេខ ០៥ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០២២ របស់ជនជាប់ចោទឈ្មោះ [redacted] ទង ហៅ ធី ប្តឹងចំពោះសាលដីកាព្រហ្មទណ្ឌលេខ ១១៦ ក្រ.V.ច ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ របស់សភាព្រហ្មទណ្ឌ នៃសាលាឧទ្ធរណ៍ភ្នំពេញ ដែលមាន ៖

-**ជនជាប់ចោទ** ៖ ឈ្មោះ [redacted] ទង ហៅ ធី ភេទប្រុស អាយុ ២៥ឆ្នាំ ជនជាតិវៀតណាម មុខរបរ នេសាទ មានទីកន្លែងកំណើតនៅសង្កាត់ជ្រោយចង្វារ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ និងមានទីលំនៅមុនពេល ឃុំខ្លួននៅ[redacted]។ ឪពុកឈ្មោះ [redacted]



Scanned with CamScanner

ម្តាយឈ្មោះ លង "វ" ប្រពន្ធឈ្មោះ [redacted] មានកូន ០១នាក់ ជាទីតិជន ទោសពីមុនគ្មាន។ (ក្នុងឃុំ) (អ្នកប្តឹងសាទុក្ខ)

**-ជាប់ចោទពីបទ ៖** ឃាតកម្មគិតទុកជាមុន ប្រព្រឹត្តនៅចំណុចបន្ទប់លេខ០៣ ផ្ទះសំណាក់ចន្ទ្រាត្រជាក់ចិត្ត ភូមិឫស្សីទី០២ សង្កាត់ស្ទឹងមានជ័យទី០៣ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ។

-មានលោក [redacted] បូរ៉ា ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

**-ដើមបណ្តឹងរដ្ឋប្បវេណី ៖** ឈ្មោះ [redacted] ស្រីមុំ ភេទស្រី អាយុ ៣៨ឆ្នាំ ជនជាតិខ្មែរ មុខរបរស៊ីឈ្នួលតាមផ្ទះ មានទីកន្លែងកំណើត និងមានទីលំនៅបច្ចុប្បន្ននៅភូមិព្រៃសំបួរ ឃុំអង្គរបុរី ស្រុកអង្គរបុរី ខេត្តតាកែវ (ត្រូវជាប្រពន្ធរបស់ជនរងគ្រោះឈ្មោះ [redacted] កើតថ្ងៃទី០១ ខែមករា ឆ្នាំ១៩៨១)។

## អំពីអង្គហេតុ

កាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៩ ជនរងគ្រោះឈ្មោះ [redacted] ជឿន ភេទប្រុស បានចេញពីផ្ទះនៅខេត្តតាកែវមកភ្នំពេញ ពេលនោះជនសង្ស័យឈ្មោះ [redacted] ទង ហៅ ធី ភេទប្រុស ក៏បានសុំគាត់មកជាមួយដើម្បីរកការងារធ្វើនៅភ្នំពេញ ហើយពេលធ្វើដំណើរតាមផ្លូវ ជនសង្ស័យបានរៀបរាប់ប្រាប់ជនរងគ្រោះថាឈ្មោះ[redacted]ផល្លា ដែលជាសង្សាររបស់ខ្លួន មិនស្មោះជាមួយខ្លួន ពេលនោះជនរងគ្រោះបានប្រាប់ជនសង្ស័យថាឈ្មោះ [redacted] ផល្លា មិនមែនជាមនុស្សល្អទេ ហើយថាគាត់ធ្លាប់បានរួមភេទជាមួយឈ្មោះ[redacted] ផល្លា នោះច្រើនដងមកហើយ ពេលឮដូចនេះជនសង្ស័យខឹងនឹងជនរងគ្រោះ ហើយឱ្យជនរងគ្រោះឈប់ម៉ូតូនៅផ្សារមួយមិនស្គាល់ឈ្មោះ រួចជនសង្ស័យបានចូលទៅក្នុងផ្សារនោះ និងបានទិញកាំបិតចុងស្រួចដងឈើមួយលាក់ទុកក្នុងកាតាប ហើយក៏ឡើងជិះម៉ូតូជាមួយជនរងគ្រោះ រួចបន្តដំណើរទៅភ្នំពេញ។ ពេលមកដល់ភ្នំពេញ ម៉ោងប្រហែល ១៤រសៀល ជនរងគ្រោះ និងជនសង្ស័យបានចូលទៅស្នាក់នៅផ្ទះសំណាក់ចន្ទ្រាត្រជាក់ចិត្តនៅម្តុំស្ពានដែកចំការដូង ដោយស្នាក់នៅបន្ទប់ ០៣ ហើយពេលទៅដល់ក្នុងបន្ទប់ជនរងគ្រោះបានឱ្យសោរម៉ូតូទៅជនសង្ស័យ ហើយប្រើជនសង្ស័យឱ្យទៅដឹកស្រី ហើយពេលនោះជនសង្ស័យក៏បានសួរជនរងគ្រោះបញ្ជាក់ម្តងទៀតពីរឿងជនរងគ្រោះធ្លាប់រួមភេទជាមួយឈ្មោះ[redacted]ផល្លា ហើយជនរងគ្រោះបានប្រាប់ថាគាត់ពិតជាធ្លាប់មែន ពេលនោះជនសង្ស័យក៏បានដកកាំបិតដែលបានលាក់ទុកនោះចាក់ទៅលើខ្លួនរបស់ជនរងគ្រោះ ត្រូវ



Scanned with CamScanner

ចំទ្រូង និងពោះ ចំនួន ១០កន្លែង និងខ្នងចំនួន ០៧កន្លែង ហើយជនសង្ស័យចេញពីផ្ទះសំណាក់ខាងលើ ដោយជិះយកម៉ូតូជនរងគ្រោះទៅលក់យកប្រាក់ ហើយក៏គេចខ្លួនបាត់។ លុះមកដល់ថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៨ ទើបសមត្ថកិច្ចស្រាវជ្រាវឃាត់ខ្លួនជនសង្ស័យខាងលើបាន។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៩២៤ "ក្រ.ល" ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១-ផ្តន្ទាទោសឈ្មោះ [redacted]ទង ហៅ ធី ភេទប្រុស អាយុ ២៧ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល អស់មួយជីវិត ពីបទ ឃាតកម្មគិតទុកជាមុន ប្រព្រឹត្តនៅចំណុចផ្ទះសំណាក់ចន្ទ្រាត្រជាក់ចិត្ត ភូមិឬស្សី២ សង្កាត់ស្ទឹងមានជ័យទី៣ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ។

២-បង្គាប់ឱ្យឈ្មោះ [redacted]ទង ហៅ ធី សងសំណងជម្ងឺចិត្តចំនួន ៤០០០$ (បួនពាន់ដុល្លារអាមេរិក) ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស្រីមុំ យោងតាមបញ្ញត្តិមាត្រា ៣៥៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៨ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted]ទង ហៅ ធី និងកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស្រីមុំ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៨។

ភាគីមានសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់កំណត់។

-បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ៩៩៧ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] ទង ហៅ ធី ដែលប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ៩២៤ "ក្រ.ល" ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

-បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ១១៦ ក្រ.V.ច ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១-ទទួលសេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខ ៩៩៧ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted]ទង ហៅ ធី ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៩២៤ "ក្រ.ល" ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ លើកលែងចំណុចទី១ នៃសេចក្តីសម្រេចត្រូវកែប្រែលើឈ្មោះ

[redacted]ទង ហៅ ធី ពីទោសដាក់ពន្ធនាគារអស់មួយជីវិត មកអនុវត្តទោសពន្ធនាគារកំណត់ ៣០ (សាមសិប)ឆ្នាំវិញ យោងតាមមាត្រា ៩៣ និងមាត្រា ៩៥ នៃក្រមព្រហ្មទណ្ឌ។ ចំណុចផ្សេងពីនេះរក្សាទុកបានការដដែល។

៣-បន្តការឃុំខ្លួនឈ្មោះ [redacted]ទង ហៅ ធី តាមនីតិវិធីច្បាប់។

-សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទ មេធាវីការពារសិទ្ធិជនជាប់ចោទ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈនៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ បើកសិទ្ធិប្តឹងតវ៉ាតាមកំណត់ច្បាប់។

-បានឃើញ បណ្តឹងសាទុក្ខលេខ ០៥ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០២២ របស់ជនជាប់ចោទឈ្មោះ [redacted]ទង ហៅ ធី ដែលប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ ១១៦ ក្រ.V.ច ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ភ្នំពេញ គ្រង់ចំណុចសេចក្តីសម្រេចទាំងមូល។

-បានឃើញ សារណាការពារក្នុងបណ្តឹងសាទុក្ខរបស់ជនជាប់ចោទឈ្មោះ [redacted]ទង ហៅ ធី ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២២។

## នាពេលសវនាការនៅចំពោះមុខតុលាការកំពូល

-ចៅក្រមរបាយការណ៍បានអានរបាយការណ៍។

-តំណាងមហាអយ្យការអមតុលាការកំពូលបានធ្វើសេចក្តីសន្និដ្ឋានថា ការសម្រេចសេចក្តីរបស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលបានសម្រេចតម្កល់សាលក្រមរបស់សាលដំបូងទុកជាបានការ ដោយគ្រាន់តែកែប្រែកំរិតទណ្ឌកម្ម ពីការផ្តន្ទាទោសអស់មួយជីវិត មកជាអនុវត្តផ្តន្ទាទោសពន្ធនាគារកំណត់ ៣០ឆ្នាំវិញ គឺមានសំអាងហេតុត្រឹមត្រូវតាមច្បាប់ ព្រោះថាជនជាប់ចោទសារភាពកំហុសរបស់ខ្លួន និងសុំបន្ធូរបន្ថយទោស។ ប៉្យាងជនជាប់ចោទមានការភ្ញាក់រលឹកអំពីអំពើប្រព្រឹត្តរបស់ខ្លួន ដូចមានក្នុងសំអាងហេតុចំណុចទី២, ទី៣ និងទី៤ នៃសាលដីកាសាលាឧទ្ធរណ៍ស្រាប់។ ហេតុដូច្នេះតំណាងមហាអយ្យការស្នើសុំក្រុមប្រឹក្សាជំនុំជម្រះសម្រេចតម្កល់សាលដីកាព្រហ្មទណ្ឌលេខ ១១៦ ក្រ.V.ច ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ ទុកជាបានការដដែល។

-ជនជាប់ចោទឈ្មោះ [redacted]ទង ហៅ ធី បានឆ្លើយថាមូលហេតុដែលខ្លួនប្តឹងសាទុក្ខមកតុលាការកំពូលនេះ គឺចង់សុំឱ្យតុលាការជួយបន្ធូរបន្ថយទោសឱ្យខ្លួនមកត្រឹម ២០ឆ្នាំ ទៅ២៥ឆ្នាំ បានហើយ។



Scanned with CamScanner

-លោកមេធាវី [redacted]បូរ៉ា ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ទង ហៅ ធី បានធ្វើសេចក្ដីសន្និដ្ឋានថា ក្នុងរឿងនេះ មេធាវីការពារនៅមុខសាលាដំបូង និងសាលាឧទ្ធរណ៍ បានស្នើឱ្យប្ដូរបទល្មើស ទៅជាមនុស្សឃាតដោយចេតនា។ ហើយសាលាឧទ្ធរណ៍ មិនបានពិចារណាឆ្លើយតបទេ ដោយទទួលយកសំអាងហេតុរបស់សាលាដំបូង និងបន្ថយទោសមក ៣០ឆ្នាំ ដោយសារគាត់សារភាពថាគាត់សម្លាប់។ នេះជាសំអាងហេតុមិនគ្រប់គ្រាន់ចូលក្នុងមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌទេ ព្រោះថាបុរសម្នាក់និយាយថា ដេកជាមួយប្រពន្ធមុខប្ដី ជាការមាក់ងាយខ្លាំងណាស់។ ហើយឈ្មោះ [redacted]ទង ក្រោយពីលឺ គាត់ខឹងខ្លាំងរហូតដល់ចូលទិញកាំបិត (នេះជាអង្គហេតុឯកភាព)។ ការទិញកាំបិត ទោះបីមិនបាននិយាយថាទិញដើម្បីសម្លាប់ ក៏ប៉ុន្តែតុលាការហាក់ឱ្យទម្ងន់ថាជាគម្រោង។ តើគាត់មានគម្រោង ឬមានត្រឹមតែជាការទិញដើម្បីការពារខ្លួន ក្រែងឈ្លោះគ្នានាពេលខាងមុខ? អ្វីៗនៅក្នុងចិត្ត (មិនទាន់ជាបទល្មើស)។ ការធ្វើដំណើរតាមផ្លូវ គាត់អាចកែប្រែចិត្ត។ មកដល់កន្លែង រឿងដដែល បានកើតដែលនាំឱ្យគាត់ខឹង ខឹងខ្លាំងមានចេតនាភ្លាមៗរួចចាក់លើជនរងគ្រោះ នេះវាមិនមែនជាគម្រោងទេ។ ទោសពីបទ ឃាតកម្មគិតទុកជាមុន ទោសមួយជីវិត (ស្មើសម្លាប់) វាទាមទារគម្រោង ការរៀបចំ ក្នុងពេលវេលាមួយសមស្រប។ អង្គហេតុកើតឡើង គ្មានអ្នកណាឃើញទេ។ ប៉ូលីសអះអាងថា មានការចាក់ ១៧កាំបិត (តាមរបាយការណ៍ប៉ូលីស) ដែលមេធាវីមិនមានរបាយការណ៍នេះទេ។ ក៏ប៉ុន្តែ [redacted] ទង ថ្លែងថា បានចាក់ពីរ ឬបីកាំបិតនាំឱ្យជនរងគ្រោះសន្លប់។ វាអាចនាំឱ្យហូរឈាមស្លាប់ ក៏អាចថាបាន នេះបង្ហាញអំពីមន្ទិល។ គាត់សារភាពថា គាត់បានប្រព្រឹត្តដោយសារកំហឹងការបង្កនាំឱ្យខឹងពីសំណាក់ជនរងគ្រោះ ដែលនេះជាកត្តាមួយ អាចនាំឱ្យសម្រាលទោសបន្ថែម។ ក៏ប៉ុន្តែ ទាំងសាលាដំបូង និងសាលាឧទ្ធរណ៍ មិនបានពិចារណា នេះជាការខ្វះខាតសំអាងហេតុ។ ដូចនេះសូមក្រុមប្រឹក្សាបដិសេធ និងបញ្ជូនត្រឡប់ទៅសាលាឧទ្ធរណ៍ ដើម្បីវិនិច្ឆ័យឡើងវិញ។

-ក្រោយពីបានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្ដាប់ចម្លើយរបស់ជនជាប់ចោទ និងសេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

១-យល់ឃើញថា បណ្ដឹងសាទុក្ខលេខ ០៥ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០២២ របស់ជនជាប់ចោទឈ្មោះ

[redacted]ទង ហៅ ធី ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជម្រះបានតាមមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងមាត្រា ៤១៧, មាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២-យល់ឃើញថា ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] ស្រីមុំ មិនបានចូលរួមសវនាការតាមការឱ្យដំណឹងរបស់មហាអយ្យការអមតុលាការកំពូលទេ ប៉ុន្តែម្ចាស់បណ្តឹងសាទុក្ខ(ជនជាប់ចោទ)បានដាក់សារណាការពារជូនតុលាការកំពូលរួចហើយ និងមានមេធាវីការពារសិទ្ធិរបស់ខ្លួនចូលរួមផងដែរនោះ តុលាការកំពូលអាចធ្វើកិច្ចពិភាក្សាដេញដោលលើសំណុំរឿងនេះបាន ស្របតាមមាត្រា៤៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៣-យល់ឃើញថា ការដែលជនជាប់ចោទ និងមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទស្នើសុំឱ្យតុលាការកំពូលកែប្រែបទល្មើសពីបទ "ឃាតកម្មគិតទុកជាមុន" ទៅជាបទ "ឃាតកម្ម" វិញដោយសំអាងហេតុថា គម្រោងក្នុងការសម្លាប់មនុស្ស គួរតែច្រើនជាងសកម្មភាពត្រឹមតែជាការទិញកាំបិត មុនពេលអំពើសម្លាប់បានកើតឡើង និងស្នើសុំឱ្យតុលាការសម្រាលទោសនោះ គឺជាការមិនត្រឹមត្រូវទេ ពីព្រោះថា សាលាដំបូង និងសាលាឧទ្ធរណ៍បានរកឃើញថា ជនជាប់ចោទមានគម្រោងគិតទុកជាមុនតាមរយៈការទិញកូនកាំបិតត្រៀមរៀបចំជាស្រេច មុនពេលដែលជនជាប់ចោទធ្វើសកម្មភាពយកកូនកាំបិតនោះមកចាក់សម្លាប់ជនរងគ្រោះ ដែលសកម្មភាពបែបនេះមានលក្ខណៈគ្រប់គ្រាន់បញ្ជាក់ពីគម្រោង ដែលបានបង្កើតឡើងមុនពេលមានអំពើបៀតបៀនទៅលើជនរងគ្រោះ។ ហេតុនេះ ការដែលសាលាដំបូង និងសាលាឧទ្ធរណ៍វាយតម្លៃថា សកម្មភាពនេះគឺជាការគិតទុកជាមុន ស្របតាមមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ គឺជាការត្រឹមត្រូវហើយ។ ម៉្យាងវិញទៀត ដោយផ្អែកលើកាលៈទេសៈនៃការប្រព្រឹត្តបទល្មើស និងការសារភាពរបស់ជនជាប់ចោទ សាលាឧទ្ធរណ៍ក៏បានផ្តល់ស្ថានសម្រាលទោសឱ្យជនជាប់ចោទរួចហើយដែរ។

៤-យល់ឃើញថា ការដែលតំណាងមហាអយ្យការអមតុលាការកំពូលស្នើសុំឱ្យតុលាការកំពូលសម្រេចតម្កល់សាលដីការបស់សាលាឧទ្ធរណ៍ទុកជាបានការ ដោយមូលហេតុថា សាលដីការបស់សាលាឧទ្ធរណ៍មានសំអាងហេតុត្រឹមត្រូវតាមច្បាប់ហើយនោះ គឺមានលក្ខណៈស្របទៅនឹងសំអាងហេតុរបស់តុលាការកំពូលខាងលើនេះ។

៥-យល់ឃើញថា បណ្តឹងសាទុក្ខរបស់ជនជាប់ចោទ មិនមានមូលហេតុនៃបណ្តឹងសាទុក្ខ តាមមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឡើយ។

៦-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ១១៦ ក្រ.V.ច ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលបានសម្រេចសេចក្តីមកនេះ ត្រឹមត្រូវតាមច្បាប់ហើយ។



Scanned with CamScanner

## ហេតុដូច្នេះសម្រេច៖

១-បដិសេធបណ្តឹងសាទុក្ខលេខ ០៥ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០២២ របស់ជនជាប់ចោទឈ្មោះ [redacted]ទង ហៅ ធី។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ១១៦ ក្រ.V.ច ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ ទុកជាបានការដដែល។

សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២២ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២២។

## សមាសភាពនៃអង្គជំនុំជម្រះ

| | | |
|---|---|---|
| ឯកឧត្តម | [redacted] | ជាប្រធាន |
| ឯកឧត្តម | [redacted] | ជាចៅក្រម |
| ឯកឧត្តម | [redacted] | ជាចៅក្រម |
| ឯកឧត្តម | [redacted] | ជាចៅក្រម |
| លោកជំទាវ | [redacted] | ជាចៅក្រម |
| លោក | [redacted] | ជាក្រឡាបញ្ជី |

---

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម។**

ថ្ងៃព្រហស្បតិ៍ ៩រោច ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ, ត្រូវនឹងថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

ថ្ងៃព្រហស្បតិ៍ ៩រោច ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ, ត្រូវនឹងថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២២

**ប្រធានអង្គជំនុំជម្រះ**

[redacted]



Scanned with CamScanner

“យើង ខួន ថាចរ៉ាត់ ក្រឡាបញ្ជីតុលាការកំពូល បញ្ជាក់ថា សាលដីកានេះ បានចូលជាស្ថាពរ នៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២២ និងមានអានុភាពអនុវត្តតាមច្បាប់។”

“សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាទ្រង់ត្រាស់បង្គាប់មកអ្នកអនុវត្តសាលដីកាឱ្យសម្រេចតាមសាលដីកានេះ និងឱ្យអាជ្ញាធរគ្រប់តំណែងគ្រប់ថ្នាក់ជួយអនុវត្តសាលដីកានេះ បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។”

ថ្ងៃព្រហស្បតិ៍ ៩រោច ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ, ត្រូវនឹងថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២២

ក្រឡាបញ្ជី

ខួន ថាចរ៉ាត់



Scanned with CamScanner